នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 21-Dec-2012, 15:16
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹង "សារណារបស់ អៀង សារី ស្តីពីច្បាប់ដែលអនុញ្ញាតឲ្យគាត់ថតខ្សែអាត់សម្លេង និង/ឬ វីឌីអូ នៅក្នុងបន្ទប់ខាងក្រោមសាលសវនាការ"**

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**
ជនជាប់ចោទ:
នួន ជា
អៀង សារី
ខៀវ សំផន

មេធាវីការពារក្តីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្តម
លោក Michael G.KARNAVAS
លោក គង់ សំអុន

លោកស្រី Anta GUISSE
លោក Arthur VERCKEN
លោក Jacques VERGÈS

## I. សេចក្តីផ្តើម និង ប្រវត្តិនីតិវិធី

១- អនុលោមតាមដីកាបង្គាប់[1] របស់អង្គជំនុំជម្រះសាលាដំបូង មេធាវីការពារក្តីរបស់ អៀង សារី ("មេធាវីការពារក្តី") បានដាក់អំណះអំណាងបង្ហាញផ្លូវច្បាប់ ដែលអនុញ្ញាតឲ្យពួកគាត់ថតខ្សែអាត់សម្លេង និង/ឬ វីឌីអូ អៀង សារី ក៏ដូចជាគ្រូពេទ្យព្យាបាលរបស់គាត់ប្រសិនបើពួកគេយល់ព្រមធ្វើដូចនេះ ខណៈដែល អៀង សារី នៅក្នុងបន្ទប់ខាងក្រោមសាលសវនាការ ("សំណើ")[2]។ នៅទីនេះ សហព្រះរាជអាជ្ញាសូមឆ្លើយតបដោយអនុលោមតាមដីកាបង្គាប់តែមួយដូចគ្នានោះ។

២- សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា មេធាវីការពារក្តីខកខានមិនបានចង្អុលបង្ហាញពីសិទ្ធិតាមផ្លូវច្បាប់ណាមួយទាក់ទងនឹងការថតខ្សែអាត់សម្លេង ឬវីឌីអូ អៀង សារី នៅក្រោម កាលៈទេសៈនេះទេ ហើយសូមជូនសេចក្តីសន្និដ្ឋានបន្ថែមទៀតថា តាមវិធានផ្ទៃក្នុង គេបានហាមឃាត់ការអនុវត្តបែបដូច្នេះ។

៣- អង្គជំនុំជម្រះនេះធ្លាប់បានរកឃើញថា អៀង សារី មានសម្បទាក្នុងការចូលរួមសវនាការ បន្ទាប់ពីមានការពិនិត្យយ៉ាងទូលំទូលាយទៅលើជនជាប់ចោទ ដោយអ្នកជំនាញផ្នែកវេជ្ជសាស្ត្រអន្តរជាតិមួយរូប កាលពីថ្ងៃទី៥ និង៦ ខែវិច្ឆិកា ឆ្នាំ២០១២[3]។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ដូច្នោះថា៖

> *សម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ ត្រូវបានវាយតម្លៃដោយគ្រូពេទ្យចិត្តសាស្ត្រជាច្រើននាក់ និងគ្រូពេទ្យជំនាញជំងឺមនុស្សចាស់មួយរូប និងត្រូវបានធ្វើរបាយការណ៍ដោយអ្នកជំនាញ បួនលើកផ្សេងៗពីគ្នា៖ នៅខែកញ្ញា ឆ្នាំ២០០៩, ខែមិថុនា ឆ្នាំ២០១១ និងនាពេលថ្មីៗនេះ នៅខែកញ្ញា និងវិច្ឆិកា ឆ្នាំ២០១២។ របាយការណ៍ពីការពិនិត្យផ្នែកវេជ្ជសាស្ត្រទាំងនេះបង្ហាញថា ក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ ជនជាប់ចោទមិនមានការចុះអន់ខ្សោយសតិបញ្ញា ឬការចងចាំណាមួយដែល*

---

[1] ឯកសារលេខ **E254** ដីកាបង្គាប់ឲ្យដាក់សារណា, ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២។

[2] ឯកសារលេខ **E254/1** សារណារបស់ អៀង សារី ស្តីពីច្បាប់ដែលអនុញ្ញាតឲ្យគាត់ថតខ្សែអាត់សម្លេង និង/ឬ វីឌីអូ នៅក្នុងបន្ទប់នៅក្រោមសាលសវនាការ, ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ (បន្ទាប់តទៅនេះហៅថា "សំណើ")។

[3] ឯកសារលេខ **E238/9** សេចក្តីសម្រេចស្តីពីសម្បទាជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ, ថ្ងៃទី២៦ វិច្ឆិកា ២០១២។

*ហួសពីអ្វីដែលរំពឹងទុកសម្រាប់មនុស្សម្នាក់វ័យដូចគាត់ឡើយ។ នាពេលថ្មីៗនេះ នៅថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០១២ គ្រូពេទ្យជំនាញជំងឺមនុស្សចាស់បានសន្និដ្ឋានថា សុខភាពរបស់ជនជាប់ចោទពុំមានការប្រែប្រួល ដែលតម្រូវឱ្យវាយតម្លៃឡើងវិញទៅលើការសន្និដ្ឋានកាលពីថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១២ របស់អ្នកជំនាញដែលតែងតាំងដោយតុលាការ ដែលថា ជនជាប់ចោទមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមការជំនុំជម្រះ។*

*មេធាវីការពារក្តី អៀង សារី មិនបានជំទាស់ទៅនឹងរបាយការណ៍ថ្មីៗរបស់អ្នកជំនាញតែងតាំងដោយតុលាការ និងគ្រូពេទ្យជំនាញជំងឺមនុស្សចាស់ទេ ហើយក៏ពុំបានផ្តល់ជាមូលដ្ឋានណាមួយ ដែលអាចឱ្យអង្គជំនុំជម្រះសាលាដំបូងបដិសេធដោយសមហេតុផលចំពោះរបាយការណ៍ជំនាញ...*[4]។

៤- អង្គជំនុំជម្រះសាលាដំបូងក៏បានសម្រេចផងដែរថា "ការតម្រូវឱ្យជនជាប់ចោទចូលរួមក្នុងដំណើរការនីតិវិធីពីបន្ទប់ខាងក្រោមសាលសវនាការ ដែលសមាជិកនៃក្រុមមេធាវីការពារក្តីរបស់គាត់ក៏អាចទាក់ទងគ្នាបានគ្រប់ពេលវេលានោះ មានភាពសមស្របទាំងស្រុងចំពោះសិទ្ធិជាសារវន្តរបស់ជនជាប់ចោទ និងក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក"[5]។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចបន្ថែមទៀតថាខ្លួន "មិនយល់ឃើញថា ការថតវីឌីអូពីបន្ទប់ខាងក្រោមសាលសវនាការ មានភាពចាំបាច់ដើម្បីធានាថា ជនជាប់ចោទត្រូវបានតាមដានយ៉ាងសមស្របនោះទេ"[6]។

៥- យ៉ាងណាក៏ដោយ ដោយមិនពេញចិត្តនឹងការវាយតម្លៃនេះ មេធាវីការពារក្តីឥឡូវនេះបានស្វែងរកប្រមូលការថតខ្សែអាត់សម្លេង និង/ឬ វីឌីអូ ដែលខ្លួនបានថ្លែងដោយត្រង់ៗថាខ្លួនមានបំណងធ្វើការជំទាស់ទៅនឹងសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញនានាដែលបានចាត់តាំងដោយអង្គជំនុំជម្រះ និងគ្រូពេទ្យ

---

[4] ឯកសារលេខ **E238/9** សេចក្តីសម្រេចស្តីពីសម្បទាជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ, ថ្ងៃទី២៦ វិច្ឆិកា ២០១២, កថាខណ្ឌទី ២៣-២៤ (ការលើកឡើងខាងក្នុងត្រូវបានលុបចោល)។

[5] ឯកសារលេខ **E238/9** សេចក្តីសម្រេចស្តីពីសម្បទាជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ, ថ្ងៃទី២៦ វិច្ឆិកា ២០១២, កថាខណ្ឌទី២១។

[6] ឯកសារលេខ **E238/9** សេចក្តីសម្រេចស្តីពីសម្បទាជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ, ថ្ងៃទី២៦ វិច្ឆិកា ២០១២, កថាខណ្ឌទី៣៦។

ជំនាញជំងឺមនុស្សចាស់ និងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង[7]។ ដូចដែលសហមេធាវីការពារក្តីអន្តរជាតិរបស់ជនជាប់ចោទបានថ្លែង នៅក្នុងតុលាការថា ការពិចារណាទាំងស្រុងដើម្បីរកហេតុផលក្នុងការធ្វើសំណើនេះ គឺដើម្បីបង្ហាញពីការទាមទារមួយដែលថា "ផ្អែកតាមវិធាន៨១(៥) គាត់មិនបានតាមដានកិច្ចដំណើរការនីតិវិធី។ នេះគឺអ្វី ដែលយើងចង់បាន"[8]។

៦- ដោយពុំមានយុត្តិសាស្ត្រគាំទ្រនៅលើចំណុចនេះ ហើយនៅចំពោះមុខវិធានផ្ទៃក្នុងដែលមានការហាមឃាត់ដល់សកម្មភាពរបស់គាត់ មេធាវីការពារក្តីបានស្វែងរកប្រមូលសិទ្ធិរបស់ខ្លួនដែលបានទាមទារធ្វើការថតខ្សែអាត់ចំពោះសិទ្ធិក្នុងការទទួលបាននូវការកាត់សេចក្តីត្រឹមត្រូវ និងសិទ្ធិក្នុងការទទួលជំនួយផ្នែកច្បាប់ពីមេធាវីការពារក្តី។ គោលការណ៍ទាំងនេះពុំមាននៅក្នុងសំណើរបស់មេធាវីការពារក្តីឡើយ។

## II. អំណះអំណាង

### ក. តាមវិធានផ្ទៃក្នុង ការថតខ្សែអាត់សម្លេង ឬ វីឌីអូ មិនត្រូវបានអនុញ្ញាតទេ

៧- មេធាវីការពារក្តី គឺច្បាស់លាស់ណាស់នៅក្នុងសំណើរបស់ខ្លួន ដែលថាគោលបំណងដែលគេចង់បាននោះ គឺដើម្បីថតខ្សែអាត់សម្លេង និងវីឌីអូ ធ្វើជាភស្តុតាង។ យ៉ាងណាក៏ដោយ អង្គជំនុំជម្រះនេះធ្លាប់បានថ្លែងយ៉ាងច្បាស់លាស់ថា ភាគីនានាត្រូវបានហាមឃាត់មិនឲ្យចាត់ធ្វើការស៊ើបអង្កេតទាំងឡាយដែលមានគោលបំណងប្រមូលភស្តុតាងនោះឡើយ[9]។ វាពុំមានភាពខុសគ្នាជាចំបងណាមួយរវាងការអនុញ្ញាតឲ្យមានការថតខ្សែអាត់ទាំងនេះ និងការអនុញ្ញាតឲ្យភាគីមួយចាត់ការ និងធ្វើកំណត់ហេតុ

[7] ឯកសារលេខ **E254/1** សំណើ ត្រង់ទំព័រទី១ (ដោយលើកឡើងពី "សិទ្ធិក្នុងការថតខ្សែអាត់" របស់មេធាវីការពារក្តី និង "រក្សាទុកកំហុសណាមួយសម្រាប់ការពិនិត្យមើលលើបណ្តឹងសាទុក្ខ")។

[8] ឯកសារលេខ **E1/147.1** ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធី, ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១២, ទំព័រទី១៤។

[9] ឯកសារលេខ **E211/2** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖ សេចក្តីជូនដំណឹងរបស់មេធាវីការពារក្តីជនជាប់ចោទ នួន ជា មកអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជា (ឯកសារ E211) , ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១២ ("ក្របខណ្ឌគតិយុត្តនៅ អ.វ.ត.ក ពុំអនុញ្ញាតឲ្យភាគីបើកកិច្ចស៊ើបសួរឡើយ")។ ឯកសារលេខ **E251** សេចក្តីសម្រេចលើសំណើសុំរបស់មេធាវីការពារក្តី ពាក់ព័ន្ធនឹងភាពមិនប្រក្រតីដែលតាមការចោទប្រកាន់ថាបានកើតឡើងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ (ឯកសារលេខ E221, E223, E224, E224/2, E234, E234/2, E241 និង E241/1), ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២, កថាខណ្ឌទី៣៧ ("សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់រួចហើយថា អនុលោមតាមវិធាន៥៥ នៃវិធានផ្ទៃក្នុង ភាគីពុំមានសិទ្ធិធ្វើការស៊ើបអង្កេតដោយខ្លួនឯងនោះទេ។ ក្រុមមេធាវីការពារក្តី អៀង សារី បានដឹងច្បាស់អំពីការហាមឃាត់នេះ")។

ស្តាប់ចម្លើយ សម្រាប់ដាក់ជាភស្តុតាងជូនដល់អង្គជំនុំជម្រះសាលាដំបូងនោះឡើយ។ ចំពោះហេតុផលនេះ ការថតខ្សែអាត់នានា គួរត្រូវបានហាមឃាត់។

៨- បន្ថែមលើនេះ ការថតខ្សែអាត់ណាមួយក៏ដោយអំពីគ្រូពេទ្យព្យាបាល ដោយមាន ឬពុំមានការអនុញ្ញាត នឹងបង្កើតបានជាការជ្រៀតជ្រែកលើសាក្សីសក្ខានុពល នៅក្នុងការរំលោភទៅលើវិធាន៣៥ ដែលហាមឃាត់ដល់ការជ្រៀតជ្រែកលើកិច្ចការរដ្ឋបាលតុលាការ ដោយរួមទាំង ការជ្រៀតជ្រែកលើ "សាក្សីណាម្នាក់ ឬលើសាក្សីសក្ខានុពលដែលកំពុងផ្តល់ បានផ្តល់ ឬអាចនឹងផ្តល់ភស្តុតាងដល់សហក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ"[10]។ គ្រូពេទ្យព្យាបាលទាំងឡាយត្រូវបានកោះហៅឲ្យមកផ្តល់សក្ខីកម្មនៅចំពោះមុខ[11] ហើយដោយសារតែសុខភាពរបស់ អៀង សារី ជាបញ្ហាមួយនៅតែបន្តទៅមុខទៀតនោះ គឺជាការច្បាស់ណាស់ដែលថា គ្រូពេទ្យព្យាបាលនានាអាចនឹងត្រូវបានកោះហៅជាថ្មីម្តងទៀត ក្នុងឋានៈជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ តាមពិត មេធាវីការពារក្តីខ្លួនឯង ពីមុនមកធ្លាប់បានស្នើសុំឲ្យកោះហៅគ្រូពេទ្យព្យាបាលនានាឲ្យធ្វើជាសាក្សី[12]។ ការស្វែងរកការថតខ្សែអាត់សេចក្តីថ្លែងនានាដោយគ្រូពេទ្យព្យាបាល និងការជជែកគ្នា*ដោយភាគីតែម្ខាង* រវាងគ្រូពេទ្យ និងមេធាវីការពារក្តី ពាក់ព័ន្ធនឹងបញ្ហាជាក់លាក់ដែលគ្រូពេទ្យនឹងត្រូវបញ្ចេញមតិនៅក្នុងតុលាការ ច្បាស់ជាបង្កើតបានជាការជ្រៀតជ្រែកលើកិច្ចការរដ្ឋបាលតុលាការជាមិនខាន។

៩- អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានស្នើសុំឲ្យគ្រូពេទ្យព្យាបាលនានា រាយការណ៍ដោយផ្ទាល់ទៅអង្គជំនុំជម្រះតែម្តង[13] ហើយមិនមែនជាតួនាទីរបស់មេធាវីការពារក្តីទេ ក្នុងការចាត់ការធ្វើការស៊ើបអង្កេតដោយស្របគ្នានោះ។ ដូចដែលមេធាវីការពារក្តីត្រូវបានទទួលការព្រមាននាពេលថ្មីៗនេះ នៅក្នុងបរិបទផ្សេងគ្នា ថា "ទង្វើរបស់មេធាវីការពារក្តី អៀង សារី បង្កើតបានជាការសម្ភាសន៍ជាមួយនឹងសាក្សីសក្ខានុពលលើបញ្ហាមួយ ដែលកំពុងស្ថិតនៅក្រោមការពិចារណារបស់អង្គជំនុំជម្រះ ហើយហួសពី

[10] វិធាន ៣៥.១(ឃ) នៃវិធានផ្ទៃក្នុង។

[11] ឯកសារលេខ **E1/125.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២។

[12] ឯកសារលេខ **E1/147.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១២, ទំព័រទី១៩។

[13] ឯកសារលេខ **E238/12** អនុស្សរណៈផ្ញើជូនក្រុមវេជ្ជបណ្ឌិតមានភារកិច្ចពិនិត្យ ព្យាបាល និង ថែទាំសុខភាព អៀង សារី នៅមន្ទីរឃុំឃាំង អ.វ.ត.ក, ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១២។

សិទ្ធិធ្វើការសាកសួរបឋម ហើយ ហេតុដូច្នេះ ការធ្វើបែបនេះពុំត្រឹមត្រូវ និងបានបំពានលើវិធានផ្ទៃក្នុងផងដែរ"[14]។

១០- សហព្រះរាជអាជ្ញាក៏បានកត់សម្គាល់ផងដែរថា បើសិនជាមេធាវីការពារក្តីធ្លាប់ស្វែងរកសុំឱ្យទទួលយកនូវខ្សែអាត់ថតសម្លេង និង/ឬវីឌីអូទាំងនេះ ជាភ័ស្តុតាងដូចដែលខ្លួនបានថ្លែងថា ខ្លួនមានបំណងចង់ធ្វើដូច្នេះមែននោះ ខ្សែអាត់ថតសម្លេង និង/ឬវីឌីអូនេះ តាមវិធានផ្ទៃក្នុង គឺមិនអាចឱ្យទទួលយកបានទេ។ តាមវិធាន៨៧(៣)នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះអាចបដិសេធលើសំណើសុំភ័ស្តុតាងដោយផ្អែកលើហេតុផលមួយចំនួន ដែលហេតុផលស្ទើរតែទាំងអស់នេះអាចយកមកអនុវត្តនៅទីនេះបាន។ ខ្សែអាត់ថតសម្លេង និង/ឬវីឌីអូទាំងឡាយដែលធ្វើឡើងដោយមេធាវីការពារក្តី គឺ "មិនមានការជាប់ទាក់ទងទេ" និង "មិនស័ក្តិសមសម្រាប់បង្ហាញភ័ស្តុតាងអំពីអង្គហេតុដែលខ្លួនចង់បង្ហាញភ័ស្តុតាងនោះឡើយ" ពាក់ព័ន្ធទៅនឹងបញ្ហាសម្បទារបស់ អៀង សារី ក្នុងការចូលរួមសវនាការ ហើយអាចជារបាយការណ៍សុខភាពប្រចាំថ្ងៃ និងតាមកាលកំណត់ទៀងទាត់ "ដែលមានភាពច្រំដែល"[15]។ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងថា "ចាំបាច់ត្រូវសង្កត់ធ្ងន់ថា ជាការតាមដានរបស់ផ្នែកវេជ្ជសាស្ត្រដែលតម្រូវឱ្យធ្វើ មិនមែនជាការតាមដានដោយចៅក្រម ឬដោយមេធាវីការពារក្តីជាបុគ្គល ឬដោយសាធារណៈជននោះទេ"[16]។ ហេតុនេះ ខ្សែវីឌីអូនេះ មិនបានផ្តល់ព័ត៌មានអ្វីដែលពាក់ព័ន្ធនោះឡើយ។

១១- ដូចដែលសហព្រះរាជអាជ្ញារង William Smith បានលើឡើងថ្លែងនៅក្នុងតុលាការហើយថា "បើសិនជាជនជាប់ចោទជ្រើសយកការដេកលក់រយៈពេលមួយម៉ោង ឬពីរម៉ោង ដោយសម្រេចចិត្តថាដេកឱ្យលក់ ជាជាងធ្វើការតាមដានដំណើរការសវនាការវិញនោះ នោះការពិតមិនមែនជាបញ្ហាទេ"។ ហេតុនេះ លោកប្រធានត្រូវតែគិតអំពីតម្លៃខ្សែវីឌីអូរបស់ជនជាប់ចោទដែលកំពុងតែដេក ដោយចងចាំអំពីភ័ស្តុតាងរបស់អ្នកជំនាញដែលថ្លែងថា គាត់មានសមត្ថភាពអាចនៅទ្រាំមិនដេកក្នុងរយៈពេលពេញមួយថ្ងៃបាន"[17]។ ខ្សែអាត់ថតសម្លេង និង/ឬវីឌីអូបែបនេះ គឺមិនស្ថិតនៅក្នុងទិសដៅតិចតួចឡើយ

[14] ឯកសារលេខ **E251** សេចក្តីសម្រេចលើសំណើសុំរបស់មេធាវីការពារក្តី ពាក់ព័ន្ធនឹងភាពមិនប្រក្រតីដែលតាមការចោទប្រកាន់ថាបានកើតឡើងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ (ឯកសារលេខ E221, E223, E224, E224/2, E234, E234/2, E241 និង E241/1), ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២, កថាខណ្ឌទី៣៨។

[15] សូមអាន វិធាន ៨៧(៣)(ក) និង(គ) នៃវិធានផ្ទៃក្នុង។

[16] ឯកសារលេខ **E1/147.1** ប្រតិចារឹកនៃកិច្ចដំណើការនីតិវិធីសវនាការ, ចុះថ្ងៃទី៤ ខែធ្នូ ២០១២, ទំព័រ១៩។

[17] ឯកសារលេខ **E1/147.1** ប្រតិចារឹកនៃកិច្ចដំណើការនីតិវិធីសវនាការ, ចុះថ្ងៃទី៤ ខែធ្នូ ២០១២, កថាខណ្ឌទី២២-២៣។

តែផ្ទុយទៅវិញដូចនៅក្នុងសំណើរបស់មេធាវីការពារក្តីបានបង្ហាញស្រាប់ហើយ អាចធ្វើឡើងដោយមានបំណងជាពិសេសណាមួយ និងប្រាកដជាកម្មវត្ថុចំបងនៃខ្សែអាត់ថតសម្លេង អៀង សារី អាចដឹងយ៉ាងច្បាស់ណាស់អំពីការថតចម្លង ហើយអាចអនុវត្តតាមការដែលគាត់បានយល់ឃើញថា ដើម្បីផលប្រយោជន៍ដ៏ប្រសើរបំផុត។

១២- លើសពីនេះ ដូចដែលបានពន្យល់នៅក្នុងកថាខណ្ឌជាប់ៗគ្នាពីខាងដើម ភ័ស្តុតាងបែបនេះ "តាមច្បាប់គឺមិនត្រូវបានអនុញ្ញាតឱ្យទេ"[18] ហើយជាការជាក់ស្តែងថា ការខំព្យាយាមដើម្បីជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីបញ្ហាសម្បទា របស់ អៀង សារី ក្នុងការចូលរួមសវនាការ ដោយពុំមានភ័ស្តុតាងអំពីកាលៈទេសៈប្រែប្រួលណាមួយចេញពីបុគ្គលិកពេទ្យនោះ គឺគ្រាន់តែជា "ចេតនាដើម្បីអូសបន្លាយពេលដល់កិច្ចដំណើរការនីតិវិធីសវនាការ ឬដោយគ្មានហេតុផលច្បាស់" តែប៉ុណ្ណោះ[19]។

## ខ. មេធាវីការពារក្តីខកខានមិនបានបង្ហាញអំពីសិទ្ធិក្នុងការថតខ្សែអាត់សម្លេង និង/ឬវីដេអូ

១៣- ការធ្វើយុត្តិកម្មចំពោះខ្សែអាត់ថតសម្លេង និង/ឬវីឌីអូ ផ្អែកទៅលើហេតុផលចំនួនពីរ។ ទីមួយ មេធាវីការពារក្តីអះអាងថា "សិទ្ធិក្នុងការថតខ្សែអាត់សម្លេង"របស់ពួកគេ[20] គឺផ្តល់យុត្តិកម្មចំពោះខ្សែអាត់ថតសម្លេង និង/ឬវីឌីអូ និងថាហេតុផលនេះត្រូវបានគាំទ្រដោយ "សិទ្ធិ របស់ អៀង សារី ក្នុងការទទួលបាននូវគ្រឿងឧបករណ៍គ្រប់គ្រាន់ សម្រាប់សម្រួលដល់ការត្រៀមរៀបចំការពារក្តី"[21] និងដើម្បី "ការពារខ្លួនឯងតាមរយៈជំនួយពីមេធាវី"[22]។ ទីពីរ មេធាវីការពារក្តីបានតវ៉ាថាការហាមឃាត់ការថតជាខ្សែអាត់សម្លេង និងវីឌីអូ គឺជាការ "បង្ខិតបង្ខំ" ដែលហេតុដូចនេះ គឺជាការរំលោភទៅលើវិធាន ២១(២)នៃវិធានផ្ទៃក្នុង នៅត្រង់ថាការហាមឃាត់នេះបានបំពានដោយគ្មានសមាមាត្រទៅលើ "សិទ្ធិជាមូលដ្ឋានក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវ ក្នុងការរៀបចំការពារក្តីរបស់ខ្លួន"របស់

[18]សូមអាន វិធាន ៨៧(៣)(ឃ) នៃវិធានផ្ទៃក្នុង។

[19] សូមអាន វិធាន ៨៧(៣)(ង) នៃវិធានផ្ទៃក្នុង។

[20] ឯកសារលេខ **E254/1** សំណើ, ត្រង់កថាខណ្ឌទី៨។

[21] ឯកសារលេខ **E254/1** សំណើ, ត្រង់កថាខណ្ឌទី១០។

[22] ឯកសារលេខ **E254/1** សំណើ, ត្រង់កថាខណ្ឌទី១៧។

អៀង សារី[23]។ សហព្រះរាជអាជ្ញានឹងលើកឡើងនូវអំណះអំណាងនីមួយៗក្នុងចំណោមអំណះអំណាងទាំងនេះដោយផ្ទាល់ប្តូរគ្នាមួយម្តងៗ។

i. *មេធាវីការពារក្តីមានគំនិតយល់ខុស "ស្តីពីសិទ្ធិក្នុងការថត(ជាខ្សែអាត់សម្លេង និងវីឌីអូ)"*

១៤- ការទាមទាររបស់មេធាវីការពារក្តីនូវ "សិទ្ធិក្នុងការថត"ដែលរួមបញ្ចូលទាំងការថត អៀង សារី នៅក្នុងបន្ទប់ខាងក្រោមសាលសវនាការ។ មេធាវីការពារក្តីបានលើកយកនូវគោលការណ៍ Siracusa ស្តីពីបទប្បញ្ញត្តិការដាក់កម្រិតត្រង់កថាខណ្ឌ៧០(ជ) និងបដិប្បញ្ញត្តិនៅ[24] ក្នុងកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មកធ្វើសម្អាង។ កថាខណ្ឌនោះបានណែនាំថា "ការថតបានគ្រប់គ្រាន់នៃ*កិច្ចដំណើរការនីតិវិធី* ត្រូវតែរក្សាទុកគ្រប់រឿងទាំងអស់"[25] ហើយលុបចោលសេចក្តីយោងណាមួយលើ "សិទ្ធិរបស់ភាគីក្នុងការថត"។ មិនមានការមន្ទិលសង្ស័យធ្ងន់ធ្ងរណាមួយដែលថា ប្រតិចារឹកប្រចាំថ្ងៃ ក៏ដូចជាឯកសារនានាដែលបានដាក់បញ្ចូលនៅក្នុងសំណុំរឿងលេខ០០២/០១ បំពេញគ្រប់តាមលក្ខខណ្ឌស្តីពី "ការថតនៃកិច្ចដំណើរការនីតិវិធីបានគ្រប់គ្រាន់" ដែលមិនអាចធ្វើបដិប្បញ្ញត្តិបាន សូម្បីតែក្នុងកាលៈទេសៈបន្ទាន់ក៏ដោយ យោងតាមគោលការណ៍ Siracusa នេះ ហេតុដូចនេះសិទ្ធិរបស់ជនជាប់ចោទក្នុងការថតកិច្ចដំណើរការនីតិវិធីមិនត្រូវបានរំលោភបំពានឡើយ។

១៥- មេធាវីការពារក្តីក៏បានពឹងផ្អែកយ៉ាងខ្លាំងផងដែរទៅលើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដែលបានអនុញ្ញាតដល់មេធាវីការពារក្តីនូវសិទ្ធិក្នុងការសន្ទនាជាមួយកូនក្តីរបស់ខ្លួននៅក្នុងមន្ទីរឃុំឃាំង[26] ("សេចក្តីសម្រេច") ក្នុងគោលបំណងបង្កលក្ខណៈងាយស្រួលដល់ការប្រាស្រ័យទាក់ទង រវាងជនជាប់ចោទ និងមេធាវីរបស់ខ្លួន។ អង្គបុរេជំនុំជម្រះបានសម្រេចថា ស្ថិតនៅក្នុងកាលៈទេសៈនេះ ការអនុញ្ញាតឲ្យថត គឺជាការចាំបាច់ដើម្បីធានាចំពោះ "ភាពគ្រប់គ្រាន់នៃឧបករណ៍សម្រាប់សម្រួលការងារ" តាមមា

[23] ឯកសារលេខ **E254/1** សំណើ, ត្រង់កថាខណ្ឌទី២០។

[24] ឯកសារលេខ **E254/1** សំណើ, ត្រង់លេខយោងជើងទំព័រលេខ៣១។

[25] ក្រុមប្រឹក្សា សេដ្ឋកិច្ច និងសង្គមកិច្ច នៃអង្គការសហប្រជាជាតិ, អនុកម្មការ នៃ អសប ស្តីពីការការទប់ស្កាត់នូវការរើសអើង និងការការពារជនជាតិភាគតិច, គោលការណ៍ Siracusa Principles ស្តីពីការកម្រិតព្រំដែន និងបដិប្បញ្ញត្តិនៅក្នុងកត្តិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, ឆ្នាំ 1984, កថាខណ្ឌទី ៧០ (ជ)។ (ការសង្កត់ធ្ងន់ដោយអក្សរទ្រេត)។

[26] ឯកសារលេខ **A371/2/12** សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតដែលបដិសេធលើសំណើសុំអនុញ្ញាតថតសម្លេង និងខ្សែវីឌីអូនៃការជួបជាមួយ អៀង សារី នៅក្នុងមន្ទីរឃុំឃាំង, ចុះថ្ងៃទី១១ មិថុនា ២០១០ (ដែលបន្តទៅទៀតនៅក្នុងនេះហៅកាត់ថា "សេចក្តីសម្រេច")។

ត្រា១៤(៣)(ខ) នៃកតិកាសញ្ញា ICCPR[27]។ មេធាវីការពារក្តីបានអះអាងថា សេចក្តីសម្រេចនេះអាចយកមកអនុវត្តបានដោយផ្ទាល់សម្រាប់សំណើភ្លាមៗរបស់ពួកគេ[28] ប៉ុន្តែការពិនិត្យឡើងវិញមួយទៅលើសេចក្តីសម្រេចនោះ បានបង្ហាញឲ្យឃើញពីភាពខុសគ្នាច្រើន។

១៦- នៅក្នុងការដាក់ឯកសាររបស់មេធាវីការពារក្តីដែលនាំឲ្យមានការធ្វើសេចក្តីសម្រេច មេធាវីការពារក្តីបានអះអាងថា ការថតសម្លេង/វីឌីអូ "គឺជាការចាំបាច់សម្រាប់ជនត្រូវចោទ ដើម្បីធ្វើការប្រាស្រ័យទាក់ទងជាមួយមេធាវីរបស់ខ្លួន" ទៅតាមការសម្រេចជ្រើសរើសដោយខ្លួនផ្ទាល់"[29] ហើយអង្គបុរេជំនុំជម្រះបានផ្អែកលើមូលដ្ឋាននៃសេចក្តីសម្រេចរបស់ខ្លួនលើការពិតដែលថាការអនុញ្ញាតឲ្យថតគឺ "មានភាពចាំបាច់សម្រាប់ការត្រៀមរៀបចំការជំនុំជម្រះក្តី និងការប្រាស្រ័យទាក់ទងជាមួយមេធាវីការពារក្តី"[30] ជាពិសេស ពីព្រោះ "ដើមបណ្តឹងឧទ្ធរណ៍បានផ្តល់ការណែនាំដល់សហមេធាវីអន្តរជាតិរបស់ខ្លួនដែលរស់នៅបរទេស"[31]។ ផ្ទុយទៅវិញ សំណើបច្ចុប្បន្ននេះត្រូវបានធ្វើឡើងយ៉ាងច្បាស់លាស់ មិនដើម្បីជួយបង្កលក្ខណៈងាយស្រួលដល់ការប្រាស្រ័យទាក់ទងរវាងជនជាប់ចោទ និងមេធាវីការពារក្តីរបស់គាត់នោះទេ ប៉ុន្តែដើម្បីបង្កើតនូវឯកសារដើម្បីដាក់ជូនជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ ឬសម្រាប់បណ្តឹងឧទ្ធរណ៍[32]។

១៧- ជាងនេះទៅទៀត អង្គបុរេជំនុំជម្រះ និងតុលាការអន្តរជាតិនានាត្រូវបានយល់យ៉ាងច្បាស់ថា ការកំណត់អំពីថាតើបរិមាណពេលវេលា និងឧបករណ៍សម្រាប់ជួយសម្រួលការងារប៉ុណ្ណា ត្រូវតែធ្វើការវាយ

---

[27] ឯកសារលេខ **A371/2/12** សេចក្តីសម្រេច, ត្រង់កថាខណ្ឌទី៣៥។

[28] ឯកសារលេខ **E254/1** សំណើ, ត្រង់កថាខណ្ឌទី៩។

[29] ឯកសារលេខ **A371/2/12** សេចក្តីសម្រេច ត្រង់កថាខណ្ឌទី២៨។

[30] ឯកសារលេខ **A371/2/12** សេចក្តីសម្រេច ,ត្រង់កថាខណ្ឌទី៣៥។ សូមអានផងដែរ ឯកសារលេខ **A371/2/12** *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី៣៣ និង៣៥។

[31] ឯកសារលេខ **A371/2/12** សេចក្តីសម្រេច ,ត្រង់កថាខណ្ឌទី៣៥។

[32] ឯកសារលេខ **E254/1** សំណើត្រង់ទំព័រ ១ ("ការថតជាខ្សែអាត់សម្លេង ឬវីដេអូ គឺជា*ការមធ្យោបាយប្រសើរបំផុត និងបង្កការរំខានតិចតួចនៃការធ្វើកំណត់ហេតុដែលត្រឹមត្រូវ និងដែលអាចធ្វើការផ្ទៀងផ្ទាត់បាន* និងការរក្សាទុកនូវកំហុសណាមួយចំនួនសម្រាប់ការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ។") ។ *ដូចគ្នានឹងខាងលើកន្លែងដែល* ត្រង់កថាខណ្ឌទី៣ (គោលបំណងនៃសំណើសុំថតជាខ្សែវីដេអូ គឺ "ដើម្បីធានាថាមានកំណត់ត្រាអំពីស្ថានភាពរបស់ អៀង សារី")។ *ដូចគ្នានឹងខាងលើកន្លែងដែល* ត្រង់កថាខណ្ឌទី១៨ (ការថតសម្លេង គឺចាំបាច់ណាស់ "សម្រាប់អង្គជំនុំជម្រះសាលាដំបូងប្រើប្រាស់។ បើសិនជាចាំបាច់ សម្រាប់ឲ្យអង្គជំនុំជម្រះតុលាការកំពូលធ្វើការពិនិត្យឡើងវិញ")។ *ដូចគ្នានឹងខាងលើកន្លែងដែល* ត្រង់កថាខណ្ឌទី២៤ ("វិធីសាស្ត្រតែមួយគត់ដែលមេធាវីការពារក្តីអាចថតសម្លេង និងរក្សាទុកកំហុសចំបងៗ ដើម្បីប្តឹងសាទុក្ខ គឺការថតសម្លេង អៀង សារី ")។

តម្លៃនៅក្នុងបរិបទនេះ។ "គឺជាលទ្ធផលដែលជៀសមិនផុតនៃសិទ្ធិនេះ និងគោលបំណងជាចំបងរបស់វាដែលថាបញ្ហាអំពីថាតើសំណើណាមួយ...មានភាពចាំបាច់សម្រាប់ការត្រៀមរៀបចំការពារក្តីដែរ ឬក៏អត់នោះ ត្រូវតែធ្វើការវាយតម្លៃដោយផ្អែកលើមូលដ្ឋាននៃករណីមួយម្តងៗ យោលទៅតាមកាលៈទេសៈ"។ ការកែសម្រួលភាពគ្រប់គ្រាន់ និងភាពចាំបាច់ គឺតម្រូវឱ្យធ្វើការវាយតម្លៃ ហើយមិនគ្រាន់តែពឹងផ្អែកទៅលើការពិតដែលថា ឧបករណ៍សម្រាប់ជួយសម្រួលការងារ ឬបរិមាណពេលវេលាត្រូវបានផ្តល់ឱ្យ"[33]។ ហេតុនេះ គឺមិនមែនជាការសមស្របទាំងស្រុង ដើម្បីធ្វើសេចក្តីសន្និដ្ឋាននោះទេ ដោយមេធាវីការពារក្តីថា ព្រោះតែការថតនៅក្នុងកាលៈទេសៈមួយ ត្រូវបានចាត់ទុកថាជា "ឧបករណ៍សម្រាប់សំរួលការងារ" ចាំបាច់មួយ ក្នុងការថតនៅក្នុងកាលៈទេសៈមួយដែលខុសពីគ្នាទាំងស្រុងចំពោះកាលៈទេសៈនាពេលបច្ចុប្បន្ននេះ គឺដូចគ្នា "ឧបករណ៍សម្រាប់សម្រួលការងារ"ចាំបាច់មួយដែរ។

១៨- តាមពិត មិនដូចនឹងការថតដើម្បីជួយសម្រួលដល់ការប្រាស្រ័យទំនាក់ទំនងឱ្យបានគ្រប់គ្រាន់ រវាងជនជាប់ចោទ និងមេធាវីរបស់ខ្លួនទេ ចេតនារបស់មេធាវីការពារក្តីដើម្បីប្រើការថតខ្សែអាត់សម្លេង និង/ឬវីឌីអូរបស់ជនជាប់ចោទដូច្នេះ និងគ្រូពេទ្យសក្តានុពលដែលកំពុងធ្វើការព្យាបាល ជាភាគីប្រមូលភ័ស្តុតាង ដើម្បីតវ៉ាទៅនឹងសេចក្តីសម្រេចផ្សេងៗរបស់អង្គជំនុំជម្រះសាលាដំបូង។ អង្គបុរេជំនុំជម្រះបានថ្លែងថា "បើសិនជាការថតខ្សែអាត់សម្លេង និង/ឬវីឌីអូជាការចាំបាច់ វាជាឧបករណ៍សម្រួលតាមមាត្រា១៤(៣)(ខ) របស់ ICCPR"[34]។ ក្នុងសេចក្តីសម្រេចនោះ ការថតខ្សែអាត់សម្លេង និង/ឬវីឌីអូត្រូវបានពិចារណាថាចាំបាច់ ដោយសារវា "ចាំបាច់សម្រាប់ការត្រៀមរៀបចំសវនាការ និងការធ្វើការប្រាស្រ័យទាក់ទងគ្នាជាមួយមេធាវី"[35]។ ប៉ុន្តែ ក្រោមកាលៈទេសៈនាពេលនេះ គោលបំណងជាមូលដ្ឋាននៃការថតខ្សែអាត់សម្លេង និង/ឬវីឌីអូ មិន "ចាំបាច់" ឡើយដោយសារមួយផ្នែកធំវា *ហួសពីអំណាច* កិច្ចស៊ើបសួរ ដូច្នេះវាមិនគ្របដណ្តប់ដោយ ICCPR ទេ។

១៩- ទាក់ទងនឹងការធានាអំពី "ពេលវេលា និងឧបករណ៍សម្រួលគ្រប់គ្រាន់" តុលាការសិទ្ធិមនុស្សអឺរ៉ុប (ECHR) បានបញ្ជាក់ពីលក្ខខណ្ឌខ្ពស់ដែលអាចប្រៀបធៀបបានដែលត្រូវតែបំពេញឱ្យបានដើម្បីបញ្ជាក់អំពីការអះអាងទៅលើចទ្បីករណ៍នេះ។ ដើម្បីបំពេញបាននូវគុណវុឌ្ឍិនេះ វាមិនត្រឹមតែជាឧបករណ៍

[33] ឯកសារលេខ **A371/2/12** សេចក្តីសម្រេច, ត្រង់កថាខណ្ឌទី៣២។

[34] **A371/2/12** សេចក្តីសម្រេច ត្រង់កថាខណ្ឌ ៣៥។

[35] **A371/2/12** សេចក្តីសម្រេច ត្រង់កថាខណ្ឌ ៣៥។

សម្រួលដែលត្រូវតែ *"ចាំបាច់"* សម្រាប់ត្រៀមរៀបចំការជំនុំជម្រះក្ដីដ៏សំខាន់ប៉ុណ្ណោះទេ"[36] ប៉ុន្តែបទប្បញ្ញត្តិនៃការធានានេះក៏ត្រូវតែ "មានឱកាសដើម្បីរៀបចំការការពារជនណាម្នាក់ ឲ្យបានសមរម្យ និងដោយគ្មានការកម្រិតចំពោះលទ្ធភាពក្នុងការដាក់អំណះអំណាងពាក់ព័ន្ធទាំងអស់ នៅចំពោះតុលាការជំនុំជម្រះ និងបើដូច្នេះ គឺដើម្បីមានឥទ្ធិពលទៅលើលទ្ធផលនៃកិច្ចដំណើរការនីតិវិធី... ត្រូវបានគេចាត់ទុកថារំលោភ *វៀរលែងតែគេមិនមានលទ្ធភាពអាចធ្វើទៅបាន*"[37]។

២០- ការបង្ហាញអំពីលក្ខខណ្ឌកំណត់ខ្ពស់នៅក្នុងរឿងក្ដីមួយនៅចំពោះមុខតុលាការសិទ្ធិមនុស្សអឺរ៉ុប ដែលនៅទីនោះ អ្នកដាក់ញត្តិតវ៉ាម្នាក់បានលើកឡើងអំពីការផ្ដល់ឧបករណ៍សម្រាប់សំរួលការងារមិនបានគ្រប់គ្រាន់ ដោយផ្អែកលើលក្ខខណ្ឌនៃការឃុំឃាំងដែលមិនអាចឲ្យយកជាគំរូបាន សម្រាប់"ការប្រមូលផ្ដុំដែលមានកម្រិតមួយសមស្រប" ដែលចាំបាច់ដើម្បីត្រៀមរៀបចំសម្រាប់ការការពារក្ដី តុលាការបានរកឃើញថា "គឺជាការច្បាស់លាស់ណាស់ថា ស្ថានភាពការឃុំឃាំងអ្នកបណ្ដឹង គឺមិនអំណោយផលដល់ការបំពេញការងារដោយប្រើខួរក្បាលដែលកំពុងតានតឹងនោះឡើយ"[38]។ ទោះបីជាមានការរកឃើញយ៉ាងនេះក៏ដោយ ក៏ប៉ុន្តែតុលាការនេះនៅតែសម្រេចថា "ទោះជាយ៉ាងណាក្ដីតុលាការនេះកត់សំគាល់ឃើញថា ពុំមានការរឹតត្បឹតទៅលើអ្នកប្ដឹងសុំឡើយ ទាក់ទងទៅនឹងសិទ្ធិក្នុងការពិនិត្យមើលសំណុំរឿង និងជំនួយពីអ្នកច្បាប់ដោយឥតគិតថ្លៃ និងដោយគ្មានការរឹតត្បឹត ត្រូវបានដាក់ឲ្យមានចំពោះអ្នកប្ដឹងសុំ"។ អាស្រ័យហេតុនេះ តុលាការពេញចិត្តថា ឧបករណ៍សម្រាប់សម្រួលការងារសមស្រប គឺមាន"[39]។

២១- មេធាវីការពារក្ដីលើកយោងសេចក្ដីអធិប្បាយទូទៅលេខ ៣២ របស់គណៈកម្មាធិការសិទ្ធិមនុស្ស ដែលពន្យល់ថា "ឧបករណ៍សម្រួលគ្រប់គ្រាន់" ត្រូវតែរាប់បញ្ចូលទាំងលទ្ធភាពក្នុងការពិនិត្យឯកសារ និងភស្តុតាង លទ្ធភាពនេះត្រូវតែរាប់បញ្ចូលទាំងសម្ភារៈទាំងអស់ដែលការិយាល័យអយ្យការមានផែនការ

[36] *រឿងក្ដី Mayzit ទល់នឹងប្រទេស Russia*, ពាក្យសុំលេខ: 63378/00, សាលក្រម, ២០ មករា ២០០៥, កថាខណ្ឌ៧៨ (សង្កត់ន័យត្រង់អក្សរទ្រេត)។

[37] *រឿងក្ដី Mayzit ទល់នឹងប្រទេស Russia*, ពាក្យសុំលេខ: 63378/00, សាលក្រម, ២០ មករា ២០០៥, កថាខណ្ឌ៧៨ (សង្កត់ន័យត្រង់អក្សរទ្រេត)។

[38] *ករណីរឿងក្ដីរបស់ Mayzit ទល់នឹង ប្រទេសរុស្ស៊ី*, ពាក្យសុំលេខ 63378/00, សាលក្រម, ចុះថ្ងៃទី២០ មករា ឆ្នាំ២០០៥, កថាខណ្ឌទី៨១។

[39] *ករណីរឿងក្ដីរបស់ Mayzit ទល់នឹង ប្រទេសរុស្ស៊ី*, ពាក្យសុំលេខ 63378/00, សាលក្រម, ចុះថ្ងៃទី២០ មករា ឆ្នាំ២០០៥, កថាខណ្ឌទី៨១។

ផ្តល់ជូនតុលាការប្រឆាំងនឹងជនជាប់ចោទ ឬជាសម្ភារៈដោះបន្ទុក។ សម្ភារៈដោះបន្ទុកគួរត្រូវបានយល់ជាការបញ្ចូលមិនគ្រាន់តែសម្ភារៈដើម្បីបង្ហាញពីភាពគ្មានទោសប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្ហាញថាអាចជួយក្នុងការការពារខ្លួន (ឧ. មានសញ្ញាបង្ហាញថា ចម្លើយសារភាពមួយមិនមែនធ្វើឡើងដោយស្ម័គ្រចិត្ត)”[40]។ តាមរចនាសម្ព័ន្ធរបស់ អ.វ.ត.ក គ្រប់ភ័ស្តុតាងទាំងអស់ដែលត្រូវប្រើក្នុងពេលជំនុំជម្រះត្រូវបានដាក់នៅក្នុងសំណុំរឿងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ឬដោយអង្គជំនុំជម្រះសាលាដំបូង ហើយមេធាវីការពារក្តីមានសិទ្ធិចូលពិនិត្យគ្រប់សម្ភារៈទាំងអស់ រួមទាំងដំណើរការធ្វើសំណើសុំបំពេញកិច្ចស៊ើបសួរតាមវិធានផង[41]។ មិនមានបញ្ហាទេដែលមេធាវីការពារក្តីថាបានពិនិត្យលើទាំងសម្ភារៈដែលអាចនឹងត្រូវបានប្រើសម្រាប់ប្រឆាំងនឹងកូនក្តីរបស់ខ្លួន និងសម្ភារៈដោះបន្ទុកផង។

២២- គណៈកម្មធិការសិទ្ធិមនុស្សបានធ្វើការបកស្រាយពីសិទ្ធិដែលបានធានានៅក្រោមមាត្រា១៤ នៃ ICCPR ថា “ដូចដែលបានរៀបចំឡើងដើម្បីផ្តល់សិទ្ធិនានាដល់ភាគី និងធានាថាសិទ្ធិទាំងនោះ *មានលក្ខណៈស្រប តាមនីតិវិធី*”[42]។ មេធាវីការពារក្តីមិនត្រូវបានគេច្រានចោលមិនឲ្យ “លើកឡើងអំពីការព្រួយបារម្ភចំពោះសម្បទារបស់លោក អៀង សារី ក្នុងការចូលរួមសវនាការ និងការចូលរួមនៅក្នុងដំណើរការនីតិវិធីប្រកបដោយប្រសិទ្ធភាពឡើយ”[43]។ តាមវិធានផ្ទៃក្នុង ឬតាមនីតិវិធីបង្ហាញភ័ស្តុតាងដទៃទៀតដោយស្មើៗគ្នានឹងសហព្រះរាជអាជ្ញា ហើយពួកគេក៏បានធ្វើដូច្នេះដដែលៗរហូតមកដល់ពេលនេះ។ តាមពិតទៅ ការប្រើប្រាស់ជាញឹកញាប់នូវបែបទនីតិវិធីផ្សេងៗរបស់មេធាវីការពារក្តី ដើម្បីជំទាស់ពីបញ្ហាសម្បទារបស់ជនជាប់ចោទ គឺជាការបញ្ជាក់ដ៏ប្រសើរបំផុតអំពីនីតិវិធី ដែលធានាឲ្យមានចំពោះពួកគាត់។

### *ii. វិធាន២១(២) មិនអាចអនុវត្តបាន*

[40] គណៈកម្មាធិការសិទ្ធិមនុស្ស, សេចក្តីអធិប្បាយទូទៅលេខ ៣២, មាត្រា១៤: សិទ្ធិស្មើភាពគ្នានៅចំពោះមុខតុលាការ និងសាលាក្តី និងសិទ្ធិទទួលបានសវនាការដោយត្រឹមត្រូវ, ២០០៧, ត្រង់កថាខណ្ឌ៣៣។

[41] វិធាន៥៥(១០), ៩៣។

[42] *រដ្ឋអាជ្ញា ទល់នឹង Duško Tadić*, សំណុំរឿងលេខ IT-94-1-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍), ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩, កថាខណ្ឌទី៥០ (សង្កត់ធ្ងន់ពីដើម *ដោយអក្សរទ្រេត* ), *ដោយបានពិភាក្សាពីករណី B. d. B និងតួកន ទល់នឹង ប្រទេសហុល្លង់ដ៍*, ការប្រាស្រ័យទាក់ទងលេខ 273/1989, ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៨៩, ឯកសាររបស់ អ.ស.ប លេខ A/44/40, 442។

[43] ឯកសារលេខ **E254/1** សំណើ, ត្រង់កថាខណ្ឌទី១៨។

២៣- មេធាវីការពារក្ដីទាមទារថា ការមិនអនុញ្ញាតឱ្យពួកគេថតខ្សែអាត់សម្លេង និង/ឬវីឌីអូ គឺជាការរំលោភលើវិធាន២១(២) ដែលចែងថា៖

*វិធានការចាប់បង្ខំទាំងឡាយណាចំពោះ [ជនជាប់ចោទ] ត្រូវធ្វើឡើងដោយ ឬស្ថិតនៅក្រោមការត្រួតពិនិត្យដោយយកចិត្តទុកដាក់ពីអាជ្ញាធរមានសមត្ថកិច្ចរបស់តុលាការ។ វិធានការដូច្នេះត្រូវតែកម្រិតតឹងរ៉ឹងបំផុតសម្រាប់តែតម្រូវការនៃដំណើរការនីតិវិធី ដោយសមាមាត្រទៅនឹងកម្រិតធ្ងន់ធ្ងរនៃបទល្មើសដែលចោទប្រកាន់ និងដោយគោរពសេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិឱ្យបានពេញលេញ។*

២៤- មេធាវីការពារក្ដីអះអាងថា "សិទ្ធិជាមូលដ្ឋានរបស់លោក អៀង សារី ក្នុងការទទួលបានសវនាការដោយត្រឹមត្រូវ ដើម្បីត្រៀមរៀបចំការពារខ្លួនរបស់គាត់"[44] អាចត្រូវបានរំលោភប្រសិនបើពួកគាត់មិនអាចថតខ្សែអាត់សម្លេង និង/ឬវីឌីអូ និងថាបើដូច្នេះវាជាការបង្ខំ។ ការអះអាងនេះមិនអាចទទួលបានទេ។ មេធាវីការពារក្ដីមានឱកាសសមហេតុផលគ្រប់បែបយ៉ាង ដើម្បីត្រៀមរៀបចំការការពារក្ដី តាមរយៈការដាក់ឯកសារផ្សេងៗ និងនៅក្នុងសវនាការ។ មេធាវីការពារក្ដីមិនបានលើកយោងអំពីករណីយុត្តិសាស្ត្រ ឬប្រភពច្បាប់សម្រាប់ជាគោលការណ៍ក្នុងការការថតខ្សែអាត់សម្លេង និង/ឬវីឌីអូ នៅក្រោមកាលៈទេសៈនេះ ថាជាសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានសវនាការដោយត្រឹមត្រូវឡើយ។ សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ បានធ្វើការសន្និតនៅលើសិទ្ធិជាមូលដ្ឋាន ក្នុងការទទួលបានសវនាការដោយត្រឹមត្រូវនៃការប្រាស្រ័យទាក់ទាក់ជាមួយមេធាវីការពារក្ដី ប៉ុន្តែការប្រាស្រ័យទាក់ទងជាមួយមេធាវីការពារក្ដីពុំមានជាបញ្ហានៅក្នុងសំណើសុំនេះទេ។ ជាថ្មីម្ដងទៀត នៅក្រោមរចនាសម្ព័ន្ធរបស់ អ.វ.ត.ក ការថតខ្សែអាត់សម្លេង និង/ឬវីឌីអូដែលមេធាវីការពារក្ដីកំពុងស្នើសុំនោះ គឺមិនមែនមិនត្រឹមតែជាសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានសវនាការដោយត្រឹមត្រូវប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវបានហាមឃាត់យ៉ាងពិតប្រាកដទៀតផង។ ដោយសារសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានសវនាការដោយត្រឹមត្រូវ មិនត្រូវបានរំលោភ ទើបការមិនអនុញ្ញាតឱ្យមានការថតខ្សែអាត់សម្លេង និង/ឬវីឌីអូក្រោមកាលៈទេសនេះ មិនអាចត្រូវបានគេពិចារណាថា "ចាប់បង្ខំ" តាមវិធាន២១ ឡើយ។

២៥- មេធាវីការពារក្ដីតវ៉ាបន្ថែមថា "ការថតខ្សែអាត់សម្លេង និង/ឬវីឌីអូ របស់មេធាវីការពារក្ដី អៀង សារី *គ្មាន*ផលប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធី ឬភាគីឡើយ"[45]។ ប៉ុន្តែ ដោយសារមេធាវីការពារក្ដីមាន

[44] **E254/1** សំណើ, ត្រង់កថាខណ្ឌ២០។

[45] **E254/1** សំណើ, ត្រង់កថាខណ្ឌ២១ (សង្កត់ន័យនូវពាក្យដើម)។

បំណងយកការថតខ្សែអាត់សម្លេង និង/ឬវីឌីអូ ទៅប្រើជាភ័ស្តុតាង ទង្វើដូច្នេះច្បាស់ណាស់ថាមានផលប៉ះពាល់ទៅលើកិច្ចដំណើរការនីតិវិធី ដោយសារផលប៉ះពាល់នេះ ជាអានុភាព អាចបន្ថយការស្នើសុំបំពេញកិច្ចស៊ើបសួររបស់ភាគី ដោយរំលោភវិធាន និងអាចការជ្រៀតជ្រែកចំពោះសាក្សីផងដែរ។

២៦- ការព្យាយាមបន្ទាប់របស់មេធាវីការពារក្តី តាមវិធាន២១(២) ដែលជាគោលការណ៍សមាមាត្រមួយ ដោយអះអាងថា "មិនច្បាស់លាស់"[46]។ ទោះបីពិតក៏ដោយ អំណះអំណាងរបស់មេធាវីការពារក្តីត្រង់គោលការណ៍នេះ កើតចេញដោយពាក្យថា "ការកម្រិតលើសិទ្ធិជាមូលដ្ឋាន"[47] ដែលជាការហាមឃាត់ការថតខ្សែអាត់សម្លេង និង/ឬវីឌីអូក្រោមកាលៈទេសៈទាំងនេះ មិនមែនជាការស្មុគ្រស្មាញដូចបានពន្យល់ខាងលើទេ។ ការលើកឡើងដោយខ្លួនឯងរបស់មេធាវីការពារក្តីចំពោះគោលការណ៍សមាមាត្រានេះ គឺខកខានមិនបានគាំទ្រចំពោះអំណះអំណាងដែលថា ការហាមឃាត់ការថតខ្សែអាត់សម្លេងនិង/ឬវីឌីអូនៅក្រោមកាលៈទេសៈនេះ គឺជាសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានសវនាការដោយត្រឹមត្រូវ។ តាមពិត ការលើកឡើងនេះគឺគ្រាន់តែដើម្បីបម្រើឲ្យការចង្អុលបង្ហាញពីចម្ងាយ រវាងការកម្រិតសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានសវនាការដោយត្រឹមត្រូវពិតប្រាកដ និងសិទ្ធិរបស់មេធាវីការពារក្តីដែលមេធាវីការពារក្តីកំពុងតែព្យាយាមបង្កើតឡើងនៅពេលនេះតែប៉ុណ្ណោះ។ សេចក្តីសម្រេចនៅក្នុងរឿងក្តី *Milošević* ដែលមេធាវីការពារក្តីបានលើកយោង គឺពាក់ព័ន្ធនឹងសិទ្ធិតំណាងរបស់ជនជាប់ចោទដោយខ្លួនឯង[48]។ សេចក្តីសម្រេចនៅក្នុងរឿងក្តី *Zigiranyirazo* និង *Stanišić* ដែលមេធាវីការពារក្តីបានពឹងផ្អែក គឺពាក់ព័ន្ធនឹងសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយមានវត្តមានរបស់ខ្លួន[49]។ មេធាវីការពារក្តីតវ៉ាអំពីសិទ្ធិក្នុងការថតខ្សែអាត់សម្លេង និង/ឬវីឌីអូ ក្នុងគោលបំណងធ្វើជាភ័ស្តុតាងតាមវិធាននានាដែលជាវិធានហាមឃាត់មិនឲ្យពួកខ្លួនធ្វើដូច្នេះ។

---

[46] **E254/1** សំណើ, ត្រង់កថាខណ្ឌ២២។

[47] **E254/1** សំណើ, ត្រង់កថាខណ្ឌ២២។

[48] សូមអាន **E254/1** សំណើ, ត្រង់កំណត់សម្គាល់ជើងទំព័រលេខ៦៧ *លើកយោង រដ្ឋអាជ្ញា ទល់នឹង Milošević*, សំណុំរឿងលេខ: IT-02-54-AR73.7, សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្គំប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើការចាត់តាំងមេធាវីការពារក្តី, ១ វិច្ឆិកា ២០០៤, កថាខណ្ឌ១៧។

[49] សូមអាន **E254/1** សំណើ, ត្រង់កំណត់សម្គាល់ជើងទំព័រលេខ៦៧ *លើកយោង Zigiranyirazo ទល់នឹងរដ្ឋអាជ្ញា* សំណុំរឿងលេខ: ICTR-2001-73-AR73, សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្គំ, ៣០ វិច្ឆិកា ២០០៦, កថាខណ្ឌ១៤ និង *រដ្ឋអាជ្ញា ទល់នឹង Stanišić & Simatović*, សំណុំរឿងលេខ: IT-03-69-AR73.2, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹងសេចក្តីសម្រេចអំពីកិច្ចដំណើរការនីតិវិធីក្នុងពេលអនាគត, ១៦ ឧសភា ២០០៨, កថាខណ្ឌ១៦-២០។

### គ. អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិជាប់មកនៅក្នុងការគ្រប់គ្រងសវនាការ

២៧- បន្ទប់ខាងក្រោមសាលសវនាការ គឺជាការពង្រីកមួយរបស់តុលាការនៅពេលដែលត្រូវបានប្រើសម្រាប់ការចូលរួមរបស់ជនជាប់ចោទដោយសារការចាំបាច់ខាងសុខភាព ឬដោយសារបញ្ហាផ្សេងៗទៀត[50] ហើយអង្គជំនុំជម្រះសាលាដំបូងបានសម្រេចកាលពីលើកមុន ទៅតាមឆន្ទានុសិទ្ធិនៃការគ្រប់គ្រងសវនាការរបស់ខ្លួនថា ការថតខ្សែអាត់សម្លេង និង/ឬវីឌីអូ ក្នុងបន្ទប់ខាងក្រោមសាលសវនាការដោយភាគីមិនត្រូវបានអនុញ្ញាតឡើយ[51]។ មេធាវីការពារក្តីមិនបានបង្ហាញមូលហេតុដែលនាំឲ្យមានការកែប្រែសេចក្តីសម្រេចនោះឡើយ។

## III. សេចក្តីសន្និដ្ឋាន

២៨- អង្គជំនុំជម្រះសាលាដំបូងក្នុងពេលថ្មីៗនេះបានបដិសេធនូវការប៉ុនប៉ងផ្សេងទៀតរបស់មេធាវីការពារក្តីក្នុងការតវ៉ាប្រកបដោយប្រសិទ្ធភាពលើសេចក្តីសម្រេចទាក់ទងនឹងសម្បទារបស់ អៀង សារី និងគុណវុឌ្ឍិ ព្រមទាំងប្រសិទ្ធភាពរបស់វេជ្ជបណ្ឌិតដែលវាយតម្លៃជនជាប់ចោទ ដោយពុំមានយុត្តិកម្មធម្មានុរូបសោះឡើយ[52]។ គេគួរអនុវត្តដូចគ្នាចំពោះឫសគុលនៃសំណើនេះដែរ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា សំណើសុំរបស់មេធាវីការពារក្តីគួរត្រូវបដិសេធចោល៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១២ | **លោកស្រី ជា លាង** សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក William Smith** សហព្រះរាជអាជ្ញារង | | |

[50] **E238/9** សេចក្តីសម្រេចស្តីពីសម្បទាជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ, ២៦ វិច្ឆិកា ២០១២, កថាខណ្ឌ២១ ("ហេដ្ឋារចនាសម្ព័ន្ធសាលសវនាការរបស់ អ.វ.ត.ក មានបន្ទប់ខាងក្រោមសាលសវនាការដែលមានបំពាក់ឧបករណ៍ពិសេស")។

[51] **E1/147.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ៤ ធ្នូ ២០១២, ទំព័រ២៧-២៨។

[52] **E238/11/1** សេចក្តីសម្រេចលើសំណើរបស់ អៀង សារី សុំឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញចំពោះសេចក្តីសម្រេចរបស់ខ្លួនដែលថា អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ និងសំណើសុំបន្ថែម, ១៩ ធ្នូ ២០១២, កថាខណ្ឌ៩, ១០។